PTI0080

# សម្ភាសន៍ជាមួយឈ្មោះ អោម វឿន ភេទស្រី អាយុ៥៥ឆ្នាំ

រស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

មុខងារសម័យខ្មែរក្រហមៈ ធ្វើពេទ្យនៅតំបន់«១១» ខេត្តកោះកុង

មុខងារបច្ចុប្បន្នៈ កសិករ

សម្ភាសន៍ដោយៈ ឡុង ដានី

សម្ភាសន៍ថ្ងៃ២២ ខែឧសភា ឆ្នាំ២០១១

០០:៣៥:២១

សរុបទំព័រៈ ១៦

ដានីៈ មីងឈ្មោះពេញឈ្មោះអីដែរ?

វឿនៈ ឈ្មោះ អោម វឿន។

ដានីៈ សព្វថ្ងៃមីងអាយុប៉ុន្មានហើយ?

វឿនៈ អាយុ៥៥ឆ្នាំហើយ។

ដានីៈ សព្វថ្ងៃមីងរស់នៅក្នុងភូមិឃុំស្រុកអីដែរ?

វឿនៈ នៅក្នុងភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។

ដានីៈ គ្រួសារមីងឈ្មោះអីដែរ?

វឿនៈ គ្រួសារខ្ញុំឈ្មោះ នាក់ ផេង។

ដានីៈ គាត់អាយុប៉ុន្មានហើយ?

វឿនៈ គាត់អាយុប្អូនខ្ញុំមួយឆ្នាំ។

ដានីៈ អញ្ចឹងគាត់អាយុ៥៤ឆ្នាំ?

វឿនៈ ចាំ!

ដានីៈ មីងមានកូនចៅទាំងអស់ប៉ុន្មាននាក់?

វឿនៈ មាន៥នាក់។

ដានីៈ ហើយ៥នាក់ហ្នឹងស្រីប៉ុន្មាន ហើយប្រុសប៉ុន្មាន?

វឿនៈ ស្រី៣នាក់ ហើយប្រុស២នាក់។

ដានីៈ ហើយមីងស្រុកកំណើតមីងនៅក្នុងភូមិឃុំស្រុកអីដែរ?

វឿនៈ នៅស្រុកទ្រាំង ខេត្តតាកែវ ឃុំខ្វាវ ភូមិក្ដីវន្ទ។

ដានីៈ ឪពុកមីងឈ្មោះអីទៅ?

វឿន៖ ឪពុកខ្ញុំឈ្មោះ អោម អេប ។

ដានី៖ សព្វថ្ងៃគាត់នៅរស់ឬក៏ស្លាប់ហើយ?

វឿន៖ គាត់ស្លាប់ហើយ ។

ដានី៖ គាត់ស្លាប់តាំងពីពេលណា?

វឿន៖ គាត់ស្លាប់តាំងពីខ្ញុំអាយុ៣ម្លេះ?

ដានី៖ តាំងពីក្មេង?

វឿន៖ ចា៎!

ដានី៖ ម្ដាយមីងឈ្មោះអីដែរ?

វឿន៖ ឈ្មោះ ឃឹម ភុន ។

ដានី៖ គាត់ស្លាប់ឬក៏នៅរស់?

វឿន៖ ស្លាប់ហើយ ។

ដានី៖ គាត់ស្លាប់តាំងពីអន្កាល់?

វឿន៖ ម្ដាយខ្ញុំស្លាប់កាលឆ្នាំ៨៨ ។

ដានី៖ មីងមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ដែរ?

វឿន៖ មាន៤នាក់ ។

ដានី៖ ស្រីប៉ុន្មានហើយប្រុសប៉ុន្មាន?

វឿន៖ ស្រី២នាក់ ហើយប្រុស២នាក់ ។

ដានី៖ មីងកូនទីប៉ុន្មាន?

វឿន៖ ខ្ញុំកូនទី៣ ។

ដានី៖ ចុះកាលពីក្មេងៗមីងមានបានរៀនសូត្រអីខ្លះទេ?

វឿន៖ ខ្ញុំអត់មានបានរៀនទេ បានរៀនតែអក្ខរកម្មហ្នឹង ។

ដានី៖ បានរៀនតែអក្ខរកម្មទេ?

វឿន៖ ចា៎!

ដានី៖ រៀនអក្ខរកម្មហ្នឹងនៅណា?

វឿន៖ រៀននៅភូមិក្ដីរន្ធហ្នឹង ។

ដានី៖ ហើយរៀនបានប៉ុន្មានឆ្នាំដែរ?

វឿន៖ អក្ខរកម្មរៀនបានមួយឆ្នាំ រៀនជាមួយចាស់ៗហ្នឹង ។

ដានី៖ រៀនមួយឆ្នាំហើយយ៉ាងម៉េចទៀតទៅ?

វឿនៈ អត់មានធ្វើអីផង មានតែជួយធ្វើចំការម៉ែធ្វើអីហ្នឹង ហើយធ្វើស្រែហ្នឹងក៏ ឈប់រៀនទៅ ។

ដានីៈ បន្ទាប់មកជួយធ្វើស្រែ?

វឿនៈ ចាំ!

ដានីៈ នៅភូមិមីងគេធ្វើស្រែឬក៏ធ្វើចំការ?

វឿនៈ គេធ្វើស្រែ ។

ដានីៈ ជួយធ្វើស្រែគាត់ហ្នឹងរហូតដល់ពេលណាទៅ?

វឿនៈ រហូតដល់អាយុ១៧ឆ្នាំ ។

ដានីៈ ដល់ពេលអាយុ១៧ឆ្នាំហើយយ៉ាងម៉េចទៀត?

វឿនៈ អាយុ១៧ហ្នឹងបានខ្ញុំចេញមកនៅជាមួយខ្មែរក្រហម ។

ដានីៈ ឆ្នាំណាបានមីងចេញមកនៅជាមួយខ្មែរក្រហម?

វឿនៈ ឆ្នាំ៧៨ ។

ដានីៈ ឆ្នាំ៧៨ហ្នឹងហេតុអីបានជាមីងចេញមកនៅជាមួយខ្មែរក្រហម?

វឿនៈ កាលហ្នឹងគេថាខ្មែរក្រហមតស៊ូអញ្ចឹង ដល់ហើយចេះតែចេញមកតស៊ូជាមួយខ្មែរក្រហមទៅ ជំនាន់ហ្នឹងយើងវៃជាមួយអាមេរិចកាំង ។

ដានីៈ យើងចេញមកតស៊ូជាមួយខ្មែរក្រហមហ្នឹង មីងស្ម័គ្រចិត្តមកមែន?

វឿនៈ ចាំ! អត់មានអ្នកណាបង្ខំទេ ។

ដានីៈ អត់មានអ្នកណាបង្ខំទេ?

វឿនៈ ចាំ! មកខ្លួនឯង ។

ដានីៈ កាលហ្នឹងមីងចេញមកតែម្នាក់ឯង ឬក៏មានដូចថាមិត្តភ័ក្រ្តមកជាមួយ?

វឿនៈ មិត្តភ័ក្រ្តនៅក្នុងភូមិហ្នឹងចេញមកជាមួយ ។

ដានីៈ ប៉ុន្មាននាក់ទៅកាលហ្នឹង?

វឿនៈ ភ្លេចហើយ ប៉ុន្តែដឹងតែច្រើនដែរកាលហ្នឹង ។

ដានីៈ កាលហ្នឹងមីងចេញដំបូង មីងនៅណាទៅ?

វឿនៈ ខ្ញុំចេញដំបូងទៅនៅភ្នំដិន ចេញពីផ្ទះទៅនៅភ្នំដិន នៅកងនារីយើង ។

ដានីៈ ទៅនៅភ្នំដិន កាលហ្នឹងកងនារីមែន?

វឿនៈ ចាំ!

ដានីៈ កាលហ្នឹងគេហៅកងនារីអីគេ?

វឿនៈ គេហៅកងនារីអញ្ចឹងហ្នង ប៉ុន្តែគេមានលេខគេ ។

ដានី: កាលហ្នឹងដូចថាគេហៅកងនារី?

វឿន: គេហៅកងនារីតំបន់ ។

ដានី: តំបន់ប៉ុន្មានកាលហ្នឹង?

វឿន: តំបន់១៣ ។

ដានី: កាលហ្នឹងពេលដែលចូលទៅកងនារីហ្នឹង គេឲ្យធ្វើអីខ្លះទៅ?

វឿន: ទៅកន្លែងកងនារីហ្នឹង ទៅកន្លែងសមរភូមិ ទៅសមរភូមិត្រៀមកន្លែងដែលយើងនៅភ្នំដិន ហ្នឹងទៅទីងទល់ដែនយួន យើងទៅត្រៀមជាមួយកងយុទ្ធជន ។

ដានី: អញ្ចឹងយើងទៅកន្លែងកងត្រៀមហ្នឹងសម្រាប់ការពារព្រំដែន?

វឿន: ចា៎!

ដានី: កាលហ្នឹងកាន់កាំភ្លើងកាន់អីការពារដែរ?

វឿន: កាន់ ។

ដានី: ហើយកាលនោះមីងមានហាត់កងទ័ពអីទេ?

វឿន: ហាត់ ។

ដានី: ហាត់នៅណាទៅ?

វឿន: ហាត់នៅផ្សារទន្ទាប់ នៅវត្តផ្សារទន្ទាប់ ។

ដានី: ហាត់ហ្នឹងហាត់យ៉ាងម៉េចខ្លះ?

វឿន: ហាត់ចូលរ៉ៃបន្ទាយ ។

ដានី: ហាត់ចូលរ៉ៃបន្ទាយហ្នឹងយ៉ាងម៉េចទៅ?

វឿន: រ៉ៃបន្ទាយយើងលូន យើងចូលតាមរបងលួសតាមអីអញ្ចឹង ជាមួយនារី ជាមួយបុរស ។

ដានី: មីងហាត់យូទេនៅទន្ទាប់ហ្នឹង?

វឿន: ហាត់បានបន្តិចហ្នឹង ហាត់បានតែមួយខែហ្នឹងហើយឈប់ ។

ដានី: ហើយយ៉ាងម៉េចទៅ ពេលដែលយើងហាត់នៅទន្ទាប់បានមួយខែហ្នឹង យើងឈប់ត្រឹមហ្នឹង ហ្នង ។

វឿន: ចា៎!

ដានី: ចុះកងនារីនៅតំបន់របស់មីងមានគ្នាប៉ុន្មាននាក់?

វឿន: មានគ្នាច្រើន ។

ដានី: មួយកងតំបន់ហ្នង?

វឿន: ចា៎!

ដានីៈ កាលហ្នឹងកន្លែងកងមីងហ្នឹង ប្រធានគេឈ្មោះអីទៅ?

វឿនៈ ប្រធានឈ្មោះ សុខា ។

ដានីៈ សុខា ហ្នឹងគាត់ប្រធានកងនារីតំបន់ហ្នឹង?

វឿនៈ ប្រធានកងបរៈសេនាធំ ។

ដានីៈ ខា មួយណា?

វឿនៈ ឥលូវមិនដឹងទៅណាទេ ព្រោះបែកគ្នាយូពេក មិនដឹងទៅណា បើជួបគ្នាក៏មិនដែលស្គាល់ ឥលូវហ្នឹងព្រោះវាយូពេក ។

ដានីៈ គាត់អ្នកស្រុកណាដែរ?

វឿនៈ អត់ដឹងគាត់នៅស្រុកណាផង ព្រោះខ្ញុំនៅតាមកងខាកងរយហ្នឹង ហើយគាត់នៅកន្លែងវរៈហ្នឹង អញ្ចឹងយើងមិនអាចស្គាល់គាត់បានទេ ។

ដានីៈ ចុះមីងមានតួនាទីអីកាលហ្នឹង?

វឿនៈ កាលហ្នឹងអត់មានតួនាទីអីទេ កូនក្រុមសមាជិកគេ ។

ដានីៈ អញ្ចឹងមីងនៅកន្លែងភ្នំដិនហ្នឹង រយៈពេលប៉ុន្មានទៅ?

វឿនៈ នៅបានរយៈពេល៦ខែ ។

ដានីៈ អញ្ចឹងក្នុងរយៈពេល៦ខែហ្នឹងយើងបានធ្វើអីខ្លះទៅ យើងបានវៃជាមួយយួននៅតាមទល់ដែនដែរឬក៏អត់ទេ ។

វឿនៈ ខ្ញុំអត់មានដែលបានវៃទេ ។

ដានីៈ ហើយធ្វើអីទៅកាលហ្នឹង?

វឿនៈ នៅគ្រាន់គេឲ្យនៅត្រៀមតាមក្រោយៗគេហ្នឹង អត់ដែលបានចូលប្រឡូកទេ ។

ដានីៈ អត់ដែលបានចូលប្រឡូកទេ?

វឿនៈ ចា៎! អត់ដែលទេ ។

ដានីៈ អញ្ចឹងគ្រាន់តែនៅត្រៀមទៅ?

វឿនៈ ចា៎! គ្រាន់នៅត្រៀមពីក្រោយៗគេទៅ ។

ដានីៈ អញ្ចឹងបន្ទាប់ពី៦ខែមក តើមីងនៅកន្លែងណាទៀត?

វឿនៈ ខ្ញុំមកនៅកោះកុង នៅអណ្ដូងទឹកខេត្តកោះកុង ។

ដានីៈ មកធ្វើអីនៅអណ្ដូងទឹកខេត្តកោះកុង?

វឿនៈ នៅទ័ពដដែល ។

ដានីៈ នៅក្នុងកងដដែលឬក៏ម៉េច?

វឿនៈ	អត់ទេ  នៅក្នុងកងគេផ្សេង  ព្រោះយើងមកពីភ្នំដិនមក  គេរើសមកចូលកងតូចៗរួមគ្នាហ្នឹង នៅកោះកុងហ្នឹង ។

ដានីៈ	អាហ្នឹងគេហៅអីវិញ?

វឿនៈ	ហៅថាស្រុកត្រពាំងរូង  គេហៅម្តុំត្រពាំងរូង ។

ដានីៈ	មកនៅត្រពាំងរូងហ្នឹង  គេមិនមែនហៅកង១៣ដូចមុនទៀតទេ?

វឿនៈ	អត់ទេ ។

ដានីៈ	គេហៅអីវិញ?

វឿនៈ	អាហ្នឹងមិនដឹងគេហៅកងអីទេ  ព្រោះខ្ញុំមកនៅហ្នឹងបានបន្តិចហើយក៏មកចូលកន្លែងពេទ្យវិញ ប៉ុន្តែពេទ្យអត់ចេះអក្សរណា  បើគេឲ្យចាក់ថ្នាំចាក់ថ្នាំទៅ  គេឲ្យលាងរបួសលាងរបួសទៅ ។

ដានីៈ	អញ្ចឹងមកនៅកន្លែងអណ្តូងទឹកបានរយៈពេលប៉ុន្មានដែរ?

វឿនៈ	មកនៅបានរយៈពេល៣ខែ ។

ដានីៈ	៣ខែបានផ្លាស់មក?

វឿនៈ	ផ្លាស់មកពេទ្យវិញ ។

ដានីៈ	ពេទ្យនៅណាទៅ?

វឿនៈ	ពេទ្យនៅកន្លែងអណ្តូងទឹក ។

ដានីៈ	អណ្តូងទឹកហ្នឹងពេទ្យអីគេ?

វឿនៈ	គេហៅពេទ្យតំបន់ដែរ ។

ដានីៈ	តំបន់អីគេ?

វឿនៈ	គេហៅតំបន់១១  តំបន់កោះកុងហ្នឹង  តែបើយកនេះហ្នឹងគេហៅកោះកុង ។

ដានីៈ	តំបន់១១នៅកោះកុងហ្នឹងហ្នង?

វឿនៈ	ហ្នឹងហើយ ។

ដានីៈ	អាហ្នឹងភូមិភាគអីគេ?

វឿនៈ	ភូមិភាគបច្ចិម ។

ដានីៈ	អញ្ចឹងចេញពី?

វឿនៈ	ចេញពីតាកែវហ្នឹងមក  មកនៅនេះ ។

ដានីៈ	អាហ្នឹងឆ្នាំណាបានមីងចេញមកនៅហ្នឹង?

វឿនៈ	ចេញមកឆ្នាំ៧៨  ចុងខែហ្នឹង១២ ។

ដានីៈ	ខែ១២ហ្នឹង  មកធ្វើពេទ្យនៅហ្នឹង?

វឿនៈ ចា៎! មកនៅអណ្តូងទឹក ។

ដានីៈ ដល់ពេលយើងមកនៅធ្វើពេទ្យហ្នឹង យើងយ៉ាងម៉េចទៅ យើងទៅរៀនពេទ្យឬក៏?

វឿនៈ ទៅរៀនធម្មតាហ្នឹង ដូចថាមានអ្នករបួសគេមកពីមុខអញ្ចឹងយើងលាងរបួសលាងអីឲ្យអ្នករបួសអញ្ចឹង ។

ដានីៈ ហើយព្យាបាលហ្នឹងយ៉ាងម៉េចដែរ?

វឿនៈ ព្យាបាលគេមានដុកទ័រគេលាងអញ្ចឹងទៅ ដាក់ស៊ីរ៉ាំងឲ្យយើងព្យាបាលអញ្ចឹងទៅ ហើយដូចថាចាក់ម្នាក់នេះមានថ្នាំអីៗអញ្ចឹង យើងលាយថ្នាំមកដាក់ចាក់ទៅ ។

ដានីៈ កាលហ្នឹងមីងចេះចាក់ថ្នាំដែរ?

វឿនៈ ចេះ ។

ដានីៈ ហើយចុះព្យាបាល?

វឿនៈ ព្យាបាលល្មមយើងអាចព្យាបាលបាន ប៉ុន្តែបើធ្ងន់ធ្ងរយើងមិនអាចព្យាបាលបានទេ ។

ដានីៈ ហើយមីងចេះព្យាបាលជម្ងឺអីខ្លះទៅ?

វឿនៈ ចេះតែព្យាបាលរបួស ហើយនឹងគ្រុនអីតិចតួចហ្នឹង បន្ទាប់បន្សំហ្នឹង ។

ដានីៈ ពេទ្យកាលហ្នឹងច្រើនមែន?

វឿនៈ ពេទ្យច្រើន ពេទ្យប្រហែលជា៩០នាក់ ជួនកាល១០០នាក់ ហើយពេលរបួសច្រើនកន្លែងគេចេះតែបំបែកគ្នាទៅ ។

ដានីៈ ប្រធានពេទ្យឈ្មោះអីទៅ?

វឿនៈ មិនដឹងឈ្មោះអីទេ អ៎! ឈ្មោះ សឹង ។

ដានីៈ ស្រីឬមួយក៏ប្រុស?

វឿនៈ ប្រុស ។

ដានីៈ អញ្ចឹងមីងនៅពេទ្យហ្នឹងរយៈពេលប៉ុន្មានដែរ?

វឿនៈ ខ្ញុំនៅកាលពី៧៥មកដល់ឆ្នាំ៧៨-៧៩ហ្នឹង កាលយួនចូលហ្នឹង ។

ដានីៈ អញ្ចឹងមីងនៅធ្វើពេទ្យរហូតដល់យួនចូលមក?

វឿនៈ ចា៎!

ដានីៈ ហើយពេទ្យហ្នឹង យើងដើរព្យាបាលពីកន្លែងណាទៅកន្លែងណា?

វឿនៈ ពេទ្យនៅកន្លែងមន្ទីរហ្នុង នៅកន្លែងមណ្ឌលហ្នុង ។

ដានីៈ នៅតាមកន្លែង?

វឿនៈ ចា៎! អាហ្នឹងដូចថាមានរបួសអីមកពីមុខអញ្ចឹង គេបញ្ជូនយកមកដាក់នៅកន្លែងហ្នឹង ។

ដានី:	អញ្ចឹងពេលរបួសអីគេបញ្ជូនមកកន្លែងហ្នឹង?

វឿន:	ចា៎!

ដានី:	ចុះប្រជាជន?

វឿន:	ប្រជាជនក៏គេបញ្ជូនមកកន្លែងហ្នឹង ។

ដានី:	ប្រជាជនភាគច្រើនឈឺអីទៅកន្លែងហ្នឹង?

វឿន:	ប្រជាជនភាគច្រើនគ្រុនចាញ់ ហើយអាខ្លះទៀតខ្វះជីវជាតិ ។

ដានី:	អ្នកជម្ងឺខ្វះជីវជាតិហ្នឹងយ៉ាងម៉េចទៅ?

វឿន:	ហើម ហើយស្ងក ។

ដានី:	អញ្ចឹងយើងព្យាបាលយ៉ាងម៉េចទៅ ជម្ងឺហើយហ្នឹង?

វឿន:	ខ្លះប្រើជាតិដែក ហើយខ្លះទៀតប្រើវីតាមីន ។

ដានី:	ហើយដល់ពេលព្យាបាលទៅជាទេ?

វឿន:	ជា ។

ដានី:	បើអ្នករបួសច្រើនតែបញ្ជូនមកពីខាងណាវិញ?

វឿន:	បញ្ជូនតាមសមរភូមិ ដូចថាសមរភូមិគេនៅតាមមុខៗទៅគេចេះតែបញ្ជូនមក ហើយគេវ៉ៃនៅណានោះតែគេបញ្ជូនមកអញ្ចឹងណា៎ ។

ដានី:	គេបញ្ជូនច្រើនទេកាលហ្នឹង?

វឿន:	ច្រើនដែរហ្នឹងកាលជំនាន់ហ្នឹង ចុះកាលជំនាន់ហ្នឹងកប៉ាល់ហោះបាញ់ផងអីផង ។

ដានី:	កាលហ្នឹងភូមិភាគបច្ចឹមនៅកន្លែងណាទៅ?

វឿន:	ភូមិភាគបច្ចឹមនៅកំពង់ស្ពឺ តែមិនដឹងនៅត្រង់កន្លែងណាទេ គ្រាន់តែដឹងថាភូមិភាគបច្ចឹម ។

ដានី:	មីងដែលមកកន្លែងភូមិភាគទេ?

វឿន:	អត់ដែលមកទេ ។

ដានី:	ហើយខាងភូមិភាគហ្នឹងគេមានដែលចុះទៅពេទ្យ ចុះទៅដេកពេទ្យដែលទេ?

វឿន:	ភូមិភាគគេម៉េចនិងចុះ បើគេដេកគេឡើងទៅភ្នំពេញវិញ ។

ដានី:	កាលហ្នឹងពីណាគេភូមិភាគ?

វឿន:	កាលហ្នឹងឈ្មោះតាអីទេ ខ្ញុំភ្លេចបាត់ហើយ ។

ដានី:	មីងអត់ចាំឈ្មោះគាត់ទេ?

វឿន:	អត់សូវចាំទេ ។

ដានី:	ចុះមីងស្គាល់ តាសាន ទេ?

វឿនៈ ស្គាល់ គាសាន គាហ្នឹងគាត់រាងចាស់ហើយឆកបន្តិចណា៎?

ដានីៈ បាទ! កាលហ្នឹងមីងស្គាល់គាត់នៅណា?

វឿនៈ ខ្ញុំទើបតែស្គាល់គាត់ដែរហ្នឹង ។

ដានីៈ ចុះកាលពីមីងនៅពេទ្យមីងស្គាល់គាត់ដែរ?

វឿនៈ អត់ដែលស្គាល់ផង ។

ដានីៈ ចុះមីងមានធ្លាប់ទៅលេងផ្ទះទេ កាលដែលមីងនៅធ្វើពេទ្យហ្នឹង?

វឿនៈ អត់ទេ ខ្ញុំទើបតែទៅឃើញឥលូវនេះ ។

ដានីៈ អញ្ចឹងយើងធ្វើពេទ្យនៅកោះកុងអីហ្នឹង?

វឿនៈ កាលហ្នឹងយើងនៅក្នុង ដូចថាឆ្លងកាត់ក្នុងតំបន់មួយគឺទាហានខាងខ្មែរយើងនេះ គេថាខ្ញុំនេះខាងខ្មែរដែរ តែយើងវាជួបគ្នាអត់បានកាលហ្នឹង ។

ដានីៈ ជួបគ្នាអត់បានម៉េច?

វឿនៈ ឲ្យតែជួបគ្នាដឹងតែបាញ់គ្នាហ្នង ហើយណាមួយទាហានជំនាន់ហ្នឹង ដូចជាទាហានខាងលន់ នល់ អីហ្នឹង ។

ដានីៈ ប៉ុន្តែយើងផុតពីលន់ នល់ ហើយហ្នឹង?

វឿនៈ ផុតពីទាហានលន់ នល់ តែនៅទាហានខាងអាមេរិច ។

ដានីៈ កាលពី៧៥?

វឿនៈ កាលសម្តេចចូលហ្នឹងហើយ ។

ដានីៈ កាលជំនាន់៣ឆ្នាំពី៧៥ដល់៧៩ ។

វឿនៈ កាលជំនាន់៣ឆ្នាំខ្ញុំអត់នេះទេ អាហ្នឹងនៅកោះកុងដដែលហ្នឹង អត់ដែលបានទៅលេងហ្នឹងទេ ។

ដានីៈ ហើយម៉េចអត់ដែលបានទៅលេង?

វឿនៈ ខ្ញុំចេះតែនឹកឃើញថាម៉ែឪស្លាប់អស់ហើយ ដល់ហើយអត់ទៅ ។

ដានីៈ ហើយម៉េចដឹងថាគាត់ស្លាប់?

វឿនៈ ព្រោះដាច់យូពេក អត់ដែលទៅលេងសោះ ខ្ញុំទើបតែទៅលេងឥលូវ ពីមុនអត់ដែលទៅសោះ ។

ដានីៈ អញ្ចឹងពីមុនអត់ដែលទៅទេ?

វឿនៈ ចា៎!

ដានីៈ ចុះមីងនៅកោះកុងហ្នឹងដល់ពេលរត់យួនហ្នឹងហ្នង?

រឿន៖ ចា៎!

ដានី៖ អត់មានផ្លាស់ទៅណាផ្សេងទៀតទេ?

រឿន៖ អត់មានផ្លាស់ទេ នៅតែហ្នឹង ។

ដានី៖ ដល់ពេលយួនចូលមក ម៉េចបានជាមិនរត់ទៅផ្ទះ?

រឿន៖ ព្រោះខ្ញុំនៅកោះកុងវាឆ្ងាយពេក នៅកោះកុងដល់ពេលរត់ទៅយើងនៅតាមជួរព្រំដែន ជួរអន្តភាពនៅតាមព្រំដែនហ្នឹងនៅហ្នឹងហ្មង អត់ទៅណាទេ ។

ដានី៖ ចុះនៅកន្លែងអណ្តូងទឹកអត់ទាន់ដល់កោះកុងផង?

រឿន៖ អត់ទាន់ដល់ តែបើគិតទៅវាក្នុងខេត្តកោះកុងតែមួយ ដូចហ្នឹងហើយនឹងខេត្តពោធិ៍សាត់អញ្ចឹងណា ។

ដានី៖ អញ្ចឹងដល់ពេលយួនចូលមក មីងរត់ជាមួយអន្តភាពហ្នឹង?

រឿន៖ ចា៎! រត់ជាមួយអន្តភាព ។

ដានី៖ កាលហ្នឹងមីងរត់ទៅណាខ្លះទៅ?

រឿន៖ ខ្ញុំរត់ទៅនៅព្រំដែនហ្នឹង តាមជួរព្រំដែន ។

ដានី៖ ជួរព្រំដែនហ្នឹងដូចថាតំបូងយើងទៅនៅជាមួយអន្តភាព ហើយមានផ្លាស់ទៅណាទៀតទេ?

រឿន៖ កាលហ្នឹងមុនដំបូងយើងរត់កាត់ព្រៃ ដែលអន្តភាពយួនឡើងមកអញ្ចឹងកាត់ព្រៃកាត់អីអញ្ចឹងហើយមិនដឹងទៅណាមកណាទេ វង្វេងវង្វាន់អស់ហើយ គេធំៗគេចាស់ជាងយើងគេនាំទៅណាទៅតាមគេទៅ ព្រោះកាលហ្នឹងខ្ញុំមិនទាន់ចាស់ដូចឥលូវទេ កាលហ្នឹងនៅរាងក្មេងដែរកាលហ្នឹងនៅត្រឹមអាយុ២០ជាងទេ ដល់ពេលអញ្ចឹងទៅគេនាំទៅណាក៏ចេះតែទៅតាមគេទៅទៅណាទៅណីទៅ ។

ដានី៖ មីងអត់ស្គាល់ផ្លូវទេ?

រឿន៖ អត់ស្គាល់ទេ កាត់ព្រៃកាត់ផ្សែងចេះតែទៅៗ ។

ដានី៖ ហើយមីងកាលជំនាន់ហ្នឹងដូចថាអត់មានអីទេ យើងមកផ្ទះជួបបងប្អូន ជួបឪពុកម្ដាយ?

រឿន៖ អត់បានមកទេ ព្រោះកាលហ្នឹងខ្លាចយួន ។

ដានី៖ ម៉េចបានជាខ្លាចយួនកាលហ្នឹង?

រឿន៖ ចេះតែខ្លាចទៅ ព្រោះកាលហ្នឹងគេថាយួនចូលមក ជំនាន់ចាស់ៗច្រើនតែនិយាយ ដល់ពេលហើយចេះតែខ្លាចតៗគ្នាទៅ អត់បានមកទេ យើងនឹកឃើញកាលជំនាន់ចាស់គេថាយកក្បាលដាំធ្មើជាចង្ក្រានធ្មើអីនោះ ដល់ពេលហើយចេះតែនឹកឃើញអញ្ចឹងចេះតែអត់បានមក ។

ដានី: ចុះមានគេនិយាយដែរ ពេលដែលយើងរត់តាមផ្លូវ?

វឿន: គ្រាន់តែនិយាយថាយួនចាក់ យកទៅដាក់គុក យកទៅរៀនសូត្រអីណាណីអញ្ចឹង ម្ទោះ ហើយចេះតែអត់ហ៊ានទេ ហើយមនុស្សស្រីធម្មតា ដូចកាលជំនាន់ ធៀវគី អញ្ចឹងតែគេ ចាប់បានហើយគឺហ្នឹងហើយ ដល់ពេលអញ្ចឹងចេះតែខ្លាចទៅ មកអត់ហ៊ានមក ។

ដានី: ចុះកាលហ្នឹងអ្នកស្រុកអ្នកភូមិមីងធ្វើពេទ្យហ្នឹងមានដែលជួបមីងទេ?

វឿន: អត់ ។

ដានី: ចុះមីងរត់ហ្នឹងរហូតមកនៅណាទៅ?

វឿន: ចុងក្រោយដែលមកពីព្រំដែនមក មកនៅតាមជំរុំដីថៃ ដែលគេហៅថាជំរុំ វ«៨» អាហ្នឹង ជាប់ដីថៃហ្នុង ។

ដានី: នៅម្តុំណាទៅ?

វឿន: អត់ស្គាល់ដែរ ដល់នៅជំរុំហ្នឹងហើយបានឡើងមកនៅដីយើង នៅជំរុំបានតិចដែរហ្នឹង ព្រោះ ខ្ញុំមិនសូវដែរនៅ មកនៅតែដីយើងហ្នឹង ។

ដានី: ចុះម៉េចបានមីងមកនៅដីយើងវិញ?

វឿន: ព្រោះយើងជនជាតិខ្មែរ ហើយយើងទៅនៅដីគេធ្វើអី ហើយណាមួយនៅដីគេ គេនិយាយ តែភាសាគេ ហើយយើងស្តាប់មិនបានដដែលនៅធ្វើអី ហើយនៅខ្មែរយើងគ្នាឯងស្រួល និយាយ ។

ដានី: មីងចូលមកនៅដីខ្មែរនៅឆ្នាំណា?

វឿន: ឆ្នាំ៩១ឬក៏៩២ទេ ខ្ញុំភ្លេចបាត់ហើយ ។

ដានី: ចុះមីងមកនៅជំរុំបានយូដែរ?

វឿន: មិនសូវនៅជំរុំទេ ព្រោះកាលហ្នឹងខ្ញុំនៅតាមកង ហើយទៅនៅជំរុំម្តងៗហ្នឹង ។

ដានី: ទៅនៅតាមកងហ្នឹង នៅណាទៅ?

វឿន: កាលមុនគេហៅអូរល្ហុងហ្នឹងសុទ្ធតែដីយើងហ្នឹង ។

ដានី: ខាងខេត្តណាអូរល្ហុងហ្នឹង?

វឿន: អូរល្ហុងហ្នឹងខាងស្រុកសំឡូត ប៉ុន្តែហ្នឹងចូលដីថៃហើយ នៅខាងអូរអានោងនេះ ហ្នឹងម្តុំអូរ អានោងហ្នឹង ប៉ុន្តែអូរអានោងគេអត់កាត់ទេ គេកាត់តែខាងអូរល្ហុងទេ ។

ដានី: គេកាត់ចូលដីថៃ?

វឿន: ចាំ!

ដានី: ហើយកាលពីមុន?

វឿន៖ កាលពីមុនអាហ្នឹងនៅដីខ្មែរយើងទេ ហើយកូនខ្ញុំអីហ្នឹងសុទ្ធតែកើតនៅក្រចែជាប់ដីថៃហ្នឹង ប៉ុន្តែនៅដីយើងនៅឡើយទេ ទាល់តែពេលនេះទៅយើងឡើងមកលើអស់ម៉ានេះហ្នឹងបានថៃវាកាប់យកដីអស់ យើងមកនៅត្រឹមគោកៗនេះ ។

ដានី៖ ចុះកាលហ្នឹងមីងរៀបការនូវ?

វឿន៖ ការហើយ ហើយមានកូន២នាក់ហើយ ។

ដានី៖ កាលហ្នឹងមីងការឆ្នាំណា?

វឿន៖ កាលហ្នឹងការឆ្នាំ៨៨ ។

ដានី៖ កាលហ្នឹងមីងអាយុប៉ុន្មានពេលដែលមីងការ?

វឿន៖ ខ្ញុំអាយុ៣០ឆ្នាំ ។

ដានី៖ ការនៅកន្លែងណា?

វឿន៖ ការនៅកន្លែងក្រចែហ្នឹង ជាប់ដីថៃ ។

ដានី៖ កាលហ្នឹងពូគាត់ធ្វើអី?

វឿន៖ គាត់អ្នកពិការហ្នឹង អត់មានធ្វើអីផង គាត់អ្នកពិការហ្នឹង ។

ដានី៖ អញ្ចឹងកាលហ្នឹងមុនការមីងធ្វើអីគេ?

វឿន៖ ខ្ញុំគេហៅកងដឹកជញ្ជូន ។

ដានី៖ ដឹកជញ្ជូននៅខាងកងពលណាដែរ?

វឿន៖ ដឹកជញ្ជូនឲ្យខាងកងពលទីប៉ុន្មានទេភ្លេចអស់ហើយ ខ្ញុំដឹកទៅខាងយើងកំពង់ស្ពឺ ។

ដានី៖ កងពលហ្នឹងរបស់ឈ្មោះអីគេ?

វឿន៖ ឈ្មោះអ៊ំ លោក ។

ដានី៖ ឈ្មោះ លោក?

វឿន៖ ចា៎! លោក ហ្នឹងអភិបាលរងនៅប្រម៉ោយហ្នឹង ។

ដានី៖ អញ្ចឹងមីងនៅដឹកជញ្ជូនហ្នឹងរហូតដល់ពេលណាទៅ?

វឿន៖ ដល់ពេលការ ។

ដានី៖ ដល់ពេលការឆ្នាំ៨៨ហ្នឹង ដល់ពេលការហើយមីងទៅនៅណាវិញ?

វឿន៖ នៅក្រចែហ្នឹងហើយបានឡើងមកនៅអូរអានោងហ្នឹង ។

ដានី៖ អូរអានោងខាងសំឡូតហ្នឹង?

វឿន៖ ចា៎!

ដានី៖ នៅក្រចែអូរអានោងហ្នឹងរហូតដល់ពេលណាទៅ?

វឿនៈ រហូតដល់៩៥ បានខ្ញុំមកនៅហ្នឹងវិញ ។

ដានីៈ ចុះម៉េចបានជាមីងមកពីក្រចែអូរអានោងមកនៅហ្នឹង?

វឿនៈ មកនៅហ្នឹងព្រោះអង្គភាពគេផ្លាស់ពីនោះមកនៅនេះ ដល់ហើយគេយកខ្ញុំមកនៅនេះ ។

ដានីៈ អង្គភាពពីណាគេ?

វឿនៈ អង្គភាពពិការហ្នឹងដែរ ។

ដានីៈ ពីណាគេជាអ្នកគ្រប់គ្រង?

វឿនៈ តាសយ ហើយនឹងបន្ទុកទីមួយហ្នឹង ។

ដានីៈ អញ្ចឹងគាត់មកនៅនេះ ហើយគាត់យកមីងមកនៅជាមួយ?

វឿនៈ ចា៎!

ដានីៈ មកឆ្នាំ៩៥ ?

វឿនៈ ចា៎!

ដានីៈ មកឆ្នាំ៩៥ហ្នឹង មីងមកនៅហ្នឹងហ្មងឬក៏ម៉េច?

វឿនៈ ចា៎! មកនៅហ្នឹងហ្មង ។

ដានីៈ ហើយពេលមីងមកនៅនេះ មីងប្រកបមុខរបរធ្វើអីទៅ?

វឿនៈ ខ្ញុំដាំស្រូវ ដាំសណ្តែក ដាំល្ង ។

ដានីៈ ហើយចុះមីងបានទៅលេងផ្ទះនៅឆ្នាំណា?

វឿនៈ ទៅឆ្នាំ៩៨ ។

ដានីៈ ហើយមីងបានទៅលេងបានប៉ុន្មានថ្ងៃ?

វឿនៈ ទៅបាន១អាទិត្យ ។

ដានីៈ ហើយពេលដែលទៅដល់ហ្នឹងម្តាយមីងគាត់នៅផ្ទះទេ?

វឿនៈ គាត់ស្លាប់តាំងពីឆ្នាំ៨៨ ។

ដានីៈ អញ្ចឹងឪពុកម្តាយមីងគាត់ស្លាប់អស់ហើយ?

វឿនៈ ស្លាប់អស់ហើយ នៅតែបងស្រីម្នាក់ហ្នឹង ។

ដានីៈ នៅបងស្រី?

វឿនៈ ប្អូនប្រុសហើយនឹងបងប្រុសស្លាប់តាំងពីជំនាន់គេវៃនោះ ។

ដានីៈ អញ្ចឹងបងស្រីរបស់មីងគាត់នៅស្រុកកំណើត?

វឿនៈ ចា៎! គាត់នៅស្រុក ។

ដានីៈ ហើយក្រោយមកមីងមានដែលទៅលេងផ្ទះទេ?

វឿន៖ អត់ដែលទៅទេ តែគាត់មកលេងខ្ញុំបាន២ដងដែរ ។

ដានី៖ ហើយមីងចង់ទៅលេងស្រុកទៀតទេ?

វឿន៖ ចង់ទៅ តែមិនសូវមានលុយមានកាក់ទេ ដល់ពេលអញ្ចឹងឲ្យគាត់មកមានលុយឲ្យគាត់ធ្វើសោហ៊ុយទៅវិញ ហើយបើខ្ញុំទៅមានតែទៅគ្នាច្រើន ហើយអស់លុយច្រើនហើយណាមួយវាឆ្ងាយ ហើយបើគាត់មកគឺមកតែម្នាក់ឯង ហើយគាត់មកម្នាក់ឯងអញ្ចឹងយើងមានសោហ៊ុយបន្តិចបន្តួចយើងឲ្យគាត់ទៅវិញទៅ ។

ដានី៖ ចុះពូអ្នកស្រុកកំណើតណាដែរ?

វឿន៖ ស្រុកគាត់នៅកំពត ។

ដានី៖ ហើយគាត់ដែលទៅលេងកំពតទេ?

វឿន៖ គាត់ទៅលេង៣ដងហើយ ទៅការក្មួយដង ហើយទៅលេងដង ។

ដានី៖ ហើយមីងមានទៅជាមួយគាត់ទេ?

វឿន៖ ទៅលេងជាមួយគាត់បានម្តង កាលទៅលេងផ្ទះនៅតាកែវ ។

ដានី៖ អ៎ទៅលេងទាំងសងខាង?

វឿន៖ ចា៎! ទៅទាំងសងខាង ។

ដានី៖ ដល់ពេលក្រោយៗមកគាត់ទៅតែម្នាក់ឯង?

វឿន៖ ចា៎! គាត់ទៅជាមួយកូន ហើយខ្ញុំនៅផ្ទះ បើទៅជាមួយគ្នាចោលផ្ទះសម្បែង ។

ដានី៖ ហើយចុះមីង ដល់ពេលបែកពីផ្ទះយូអញ្ចឹង ហើយទៅលេងផ្ទះមានប្លែកទេ?

វឿន៖ ប្លែក ។

ដានី៖ ប្លែកយ៉ាងម៉េចទៅ?

វឿន៖ ប្លែកពីមុនហើយនឹងផ្លូវ ផ្លូវគេអនុវត្តន៍ជាងមុន ពីមុនអត់ដូចផ្លូវទេ កាលមកនេះមុនដំបូងព្រៃស្ទុះហើយ មានអី ទើបតែមកនៅហ្នឹងបានដាំស្វាយដាំអីហ្នឹង ដាំដូង ។

ដានី៖ ដល់ផ្លូវបានទៅជាភូមិ?

វឿន៖ ផ្លូវបានទៅជាភូមិ ដំណាំអីយើងបានហូប ។

ដានី៖ កាលពីមុនសុទ្ធតែព្រៃមែន?

វឿន៖ សុទ្ធតែព្រៃ ពេលដែលមកដល់ហ្នឹងព្រៃសុទ្ធហ្នង កាលពីមុនមកតែ៤០គ្រួសារទេ តែផ្លូវហ្នឹងមានដល់៣០០គ្រួសារ ។

ដានី៖ ភូមិដីក្រហមហ្នឹងមានដល់៣០០គ្រួសារដាង?

វឿន៖ ចា៎!

ដានី៖ អញ្ចឹងបានន័យថាអ្នកនៅក្នុងៗហ្នឹងមកនៅហ្នឹងដែរ?

វឿន៖ ចា៎! ចេះតែមកនៅបន្តបន្ទាប់ ហើយអ្នកក្នុងភូមិនេះមានកូនការបន្តបន្ទាប់ ។

ដានី៖ បែកគ្រួសារ?

វឿន៖ ចា៎! បែកគ្រួសារ ។

ដានី៖ ពេលយើងការបែកកូនបែកចៅ ហើយមានផ្ទះមានអីហ្នឹង?

វឿន៖ បែកផ្ទះអញ្ចឹងយើងកើនកាន់តែច្រើន ។

ដានី៖ អញ្ចឹងមាន៣០០គ្រួសារជាង?

វឿន៖ ចា៎!

ដានី៖ ចុះមីងដូចថាមិត្តភ័ក្រ្តរបស់នៅកាលពីនៅក្មេងៗ ហើយពេលដែលមីងទៅលេងហ្នឹងគេមានស្គាល់មីងទេ?

វឿន៖ ស្គាល់ ដូចមិត្តភ័ក្រ្តដែលរាប់គ្នាជាពួកម៉ាកហ្នឹង ហើយបងៗដែលបងយើងមួយឆ្នាំពីរឆ្នាំហ្នឹងនៅស្គាល់គ្នា ។

ដានី៖ នៅមើលស្គាល់គ្នាដែរ?

វឿន៖ ស្គាល់ ។

ដានី៖ ចុះមីងមានដែលឮសាលាក្តីជំនុំជំរះកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទេ?

វឿន៖ ឮតាវិទ្យុ ។

ដានី៖ ហើយមកដល់សព្វថ្ងៃមីងមានដឹងថាគេជំនុំជំរះទោសដល់ណាទេ?

វឿន៖ ចេះតែឮតាមវិទ្យុគេថាកាត់ទោសលេខ០០១ លេខ០០២ ។

ដានី៖ ០០១ហ្នឹងពីណាគេ?

វឿន៖ តាមថា០០១ហ្នឹង តាឌុច ។

ដានី៖ ស្គាល់ តាឌុច ទេ?

វឿន៖ អត់ស្គាល់ទេ តែឮសូរតែឈ្មោះហ្នឹង ។

ដានី៖ ហើយមានដែលឃើញមុខគាត់ទេ?

វឿន៖ អត់ដែលទេ ។

ដានី៖ ចុះ០០២?

វឿន៖ ០០២ហ្នឹងក៏ឮតែឈ្មោះ ។

ដានី៖ ពីណាគេ?

វឿនៈ	គ្រាន់តែឮឈ្មោះថា ខៀវ សំផន, នួន ជា, តាម៉ុក, អៀង សារី ហើយមានតាប៉ុល ពត អាហ្នឹងគ្រាន់តែឮគេថាទេ តែមិនដែលឃើញផង ។

ដានីៈ	ចុះកាលតស៊ូមីងមានដែលជួបទេ?

វឿនៈ	អត់ដែលជួបទេ ។

ដានីៈ	ចុះចំពោះមីងវិញ មីងយល់ឃើញយ៉ាងម៉េចដែរ ដូចថាអង្គការសហប្រជាជាតិគេបង្កើតជាសាលាក្តីដើម្បីកាត់ទោសពួកគាត់ហ្នឹង ហើយបើតាមចិត្តមីង តើមីងយល់ឃើញយ៉ាងម៉េចដែរ?

វឿនៈ	អត់មានយល់ឃើញអីទេ អាហ្នឹងបើថាតាមចិត្តរបស់ខ្ញុំដូចថាអង្គការសហប្រជាជាតិហើយនឹងរដ្ឋាភិបាលមើលឃើញទោសកំហុសគាត់ម៉េច អាហ្នឹងតាមទោសកំហុសរបស់គាត់ទៅ បើចំពោះខ្ញុំវិញអត់មានបញ្ហាអីទេ គាត់ក៏ខ្ញុំមិនដែលមានបញ្ហាអីជាមួយគាត់ ជាមួយរដ្ឋាភិបាលក៏ខ្ញុំមិនដែលមាន ហើយរាល់ថ្ងៃមិនដែលឃើញមុខផង ឃើញតែតាមទូរទស្សន៍ ហើយរដ្ឋាភិបាលក៏អញ្ចឹង ។

ដានីៈ	ហ៊ុន សែន ហ្នឹង?

វឿនៈ	ចា៎! សម្តេចហ៊ុន សែន ក៏ខ្ញុំមិនដែលទៅបានឃើញមុខគាត់ផ្ទាល់ ហើយបើតាមទស្សនៈទោះបីខាងលើកាត់ទោសម៉េចក៏មិនមានបញ្ហាអី ហើយកាលខ្ញុំរស់នៅក្នុងព្រៃក៏ខ្ញុំមិនដែលមានបញ្ហាអី វារស់នៅដោយកន្ទែង ដូចថាកន្ទែងខ្វះហូបបបរហូបអីអញ្ចឹង តែបើកន្ទែងខ្ញុំរស់នៅវាអត់ ហូបសមរម្យ មួយថ្ងៃបីពេលតាមដែលប៉ុល ពត គាត់ប្រកាសអញ្ចឹង ។

ដានីៈ	អញ្ចឹងមីងខ្ញុំដូចជាអស់សំនួរអីត្រូវសួរមីងទៀតហើយ អញ្ចឹងមីងមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំមិនទាន់បានសួរមីងទេ ។

វឿនៈ	ដូចជាអត់មានអីទៀតទេ បើថាឆ្ងល់ពីរឿងកាត់ទោសទៅ តែកាត់ទោសហ្នឹងមិនដឹងជាយកគាត់កាត់ទោសដល់ណាទេ ឆ្ងល់រាល់ថ្ងៃថាមិនដឹងយកគាត់កាត់ទោសដល់ណាទេ បើគាត់ចំណាស់ហ្នឹងហើយ មិនដឹងជាអាយុជីវិតគាត់រស់បានប៉ុន្មានទៀតទៅ ។

ដានីៈ	អានេះបើតាមខ្ញុំយល់វិញ វាទាក់ទងតាមផ្លូវច្បាប់ អញ្ចឹងហើយបានជាគេអត់មានកំណត់អាយុថា អាយុប៉ុណ្ណេះត្រូវទទួលទោស ហើយអាយុប៉ុណ្ណេះមិនត្រូវកាត់ទោសទេ ហើយបើសិនជាយើងមានអាយុចាប់ពី១៨ឆ្នាំឡើងទៅអាហ្នឹងត្រូវតែទទួលទោសចំពោះមុខច្បាប់ អញ្ចឹងហើយទោះជាគាត់ចាស់យ៉ាងម៉េច ដូចថាគាត់ចាស់អញ្ចឹង តែចំពោះច្បាប់គេអត់និយាយអញ្ចឹងទេ គេគិតថាបើគាត់មានទោសគាត់ត្រូវតែទទួលទោស ហើយរាល់ថ្ងៃនេះគាត់នៅក្នុងដំណើរការកាត់ទោសនៅឡើយ ហើយគេអត់ទាន់បើកសវនាកាត់ទោសគាត់ជា

ផ្លូវការនៅឡើយទេ ពីមុនៗមកច្រើនតែទាក់ទងហ្នឹងនិតិវិធីថាគាត់ប្តឹងសុំនៅក្រោយយ៉ាងម៉េចៗនៅតុលាការគេបើកសាវនាការកាត់ក្តីថ្ងៃហ្នឹង តែចំពោះអង្គសេចក្តីកាត់ទោសគាត់ថាគាត់មានទោសយ៉ាងម៉េច ចោទប្រកាន់គាត់ថាគាត់មានទោសហ្នឹងវាអត់ទាន់ទេ វាអត់ទាន់កាត់នៅឡើយទេ ហើយនៅថ្ងៃ២៧ ខែ១០ ៩ខាងមុខហ្នឹងគេនឹងចាប់ផ្តើមដែលគេហៅថាសាវនាការបឋម ទាក់ទងនឹងជំនុំជំរះការកាត់ទោសលេខ០០២ ។ អញ្ចឹងខ្ញុំសូមអរគុណមីងច្រើនដែលបានចំណាយពេលសំណេះសំណាលជាមួយខ្ញុំ ។

វឿនៈ ចាំ!